(៥៦៦) ៥៤៣

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

លេខ ៣៤......ប្រ.ក/សណ.

២១.៦.០១

# ប្រកាស

## ស្តីពី

## ការគ្រប់គ្រងការដ្ឋានសំណង់

រដ្ឋមន្ត្រី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត / ១១៩៨ /៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៦៩៩ /០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- បានឃើញព្រះរាជក្រម លេខ ០៤ /នស /៩៤ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និង សំណង់
- បានឃើញអនុក្រឹត្យ លេខ ៦២ អនក្រ /បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- បានឃើញអនុក្រឹត្យ លេខ ៨៦ / អនក្រ / បក ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ / បក ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៩៤ ស្តីពីសណ្តាប់ធ្នាប់សាធារណៈនៅរាជធានីភ្នំពេញ និង ខេត្ត ក្រុង
- បានឃើញប្រកាស លេខ ៧៥ ប្រក / ដនស ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៩៩ ស្តីពីការគ្រប់គ្រងសហគ្រាស ក្រុមហ៊ុន សិក្សាគំរោងប្លង់ និង សាងសង់
- បានឃើញប្រកាស លេខ ៧៦ ប្រក / ដនស ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៩៩ ស្តីពីតួនាទី ភារកិច្ច ចេទាសម្ព័ន្ធរបស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី ខេត្ត ក្រុង និង តួនាទី ភារកិច្ចរបស់បណ្តាការិយាល័យក្រោមឱវាទ
- ផ្អែកលើសភាពការណ៍នៃស្ថានភាពសំណង់បច្ចុប្បន្ន ។

សម្រេច

៤៤៦(៤៦២)

ប្រកាសនេះ មានគោលបំណងរក្សាសណ្តាប់ធ្នាប់ សន្តិសុខសាធារណៈ និង សុវត្ថិភាព ក្នុងការដ្ឋានសំណង់ ព្រមទាំងពង្រឹងការអនុវត្តបទប្បញ្ញត្តិនានាដែលទាក់ទងនឹងការសាងសង់សំដៅបង្កើនគុណភាព និង សោភ័ណភាព។

ប្រការ ២.-

អាចអនុញ្ញាតឱ្យបើកការដ្ឋានដំណើរការបានចំពោះតែសំណង់ណាដែល សហគ្រាស ក្រុមហ៊ុន ឬ ក្រុមជាងម៉ៅការសាងសង់ មានលិខិតអនុញ្ញាតប្រកបអាជីវកម្មសាងសង់ចេញឱ្យដោយ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ឬមន្ទីរ រៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្ត ក្រុង ។

ប្រការ ៣.-

ការដ្ឋានទីមួយៗ អាចដំណើរការបានលុះត្រាតែមានលិខិតអនុញ្ញាតបើកការដ្ឋាន ។

លិខិតអនុញ្ញាតបើកការដ្ឋានត្រូវសុំនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ឬ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី ខេត្ត ក្រុង ក្នុងរយៈពេលមួយខែយ៉ាងយូរបន្ទាប់ពីទទួលបានលិខិតអនុញ្ញាតសាងសង់ ។

សំណុំឯកសារដើម្បីសុំលិខិតអនុញ្ញាតបើកការដ្ឋានមាន :

១-ពាក្យសុំរបស់ម្ចាស់សំណង់

២-លិខិតអនុញ្ញាតសាងសង់

៣-កិច្ចសន្យារវាងម្ចាស់សំណង់ និង សហគ្រាស ក្រុមហ៊ុន ឬ ក្រុមជាងម៉ៅការសាងសង់

៤-លិខិតអនុញ្ញាតប្រកបអាជីវកម្មសាងសង់ របស់សហគ្រាស ក្រុមហ៊ុន ឬក្រុមជាងម៉ៅការសាងសង់ ដែលទទួលសំណង់នោះ ។

ប្រការ ៤.-

ការដ្ឋានសំណង់នីមួយៗត្រូវ :

-តំកល់ជាប្រចាំ លិខិតបើកការដ្ឋាន . គំនូរប្លង់តាមមុខជំនាញការងារសំណង់ . ផែនការអនុវត្តការងារក្នុងដំណាក់កាលនីមួយៗនៃការសាងសង់ និង ឯកសារ ពាក់ព័ន្ធ ទុកសម្រាប់ភ្នាក់ងារសំណង់តាមដានត្រួតពិនិត្យ

-មានអ្នកបច្ចេកទេសសំណង់សម្រាប់ទទួលខុសត្រូវក្នុងការងារសាងសង់ ហើយមានកាតព្វកិច្ចឆ្លើយបំភ្លឺផ្តល់ព័ត៌មានជូនដល់ភ្នាក់ងារមានសមត្ថកិច្ចត្រួតពិនិត្យ

-ដាក់ផ្ទាំងគំនូរសំណង់ ដែលមានឈ្មោះសំណង់ នៃអគារត្រូវសាងសង់ .ក្រុមហ៊ុនសំណង់ .ម្ចាស់សំណង់ . ស្ថាបត្យករ . វិស្វករ . ថ្ងៃក្រឡាសំណង់ . លេខទូរស័ព្ទទាក់ទង និងកន្លែងការដ្ឋានតាំងនៅ

-មានភ្លើងដើម្បីបំភ្លឺ និង ត្រូវមានប្រដាប់សម្រាប់ពន្លត់អគ្គីភ័យជាប្រចាំ

-បន្ថយការរំខានដោយស្នូរសំលេង ផ្សែង ធូលី និង ផលប៉ះពាល់ដទៃទៀត ឱ្យស្ថិតនៅក្នុងកំរិត និង ពេល

វេលាមួយដែលអ្នករស់នៅជុំវិញការដ្ឋានអាចទទួលបាន ។

ប្រការ ៥.-

ការដ្ឋានទីមួយៗ ត្រូវហ៊ុមព័ទ្ធដោយរបងមានកម្ពស់ ២ម៉ែត្រ យ៉ាងទាបបំផុត ហើយមិនអនុញ្ញាតឱ្យធ្វើលើចិញ្ចើមថ្នល់ ។ ក្នុងករណីទីតាំងការដ្ឋានចង្អៀត ការធ្វើរបងបិទបាំងបណ្តោះអាសន្នលើចិញ្ចើមថ្នល់សាធារណៈ ត្រូវរក្សាឱ្យមានចន្លោះផ្លូវដើរលើចិញ្ចើមថ្នល់ និង ធ្វើរបាំងការពារតាមទំហំដែលអនុញ្ញាត ឬ កំណត់ដោយអាជ្ញាធរមានសមត្ថកិច្ច ។ ចំពោះសំណង់ដែលមានកម្ពស់ចាប់ពី ៩ម៉ែត្រឡើងទៅ ត្រូវហ៊ុមព័ទ្ធដោយក្រណាត់កៅស៊ូ ឬសំណាញ់សុវត្ថិភាព ។

ប្រការ ៦.-

ការដ្ឋានត្រូវមានសណ្តាប់ធ្នាប់ និង អនាម័យ ជាប្រចាំ តាំងពីពេលចាប់ផ្តើមដំណើរការរហូតដល់ពេលបញ្ចប់ការដ្ឋាន ។ ម្ចាស់សំណង់ជាអ្នកទទួលខុសត្រូវចំពោះការ រៀបចំសណ្តាប់ធ្នាប់ និង អនាម័យដែលបណ្តាលមកពីការទុកដាក់សម្ភារៈ ឬ កាកសំណល់ឱ្យប៉ះពាល់ផ្លូវសាធារណៈ ឬ ហូរធ្លាក់ចូលក្នុងអាងត្រួតពិនិត្យ នៃបណ្តាលូ និង ប្រឡាយទឹក ។

ប្រការ ៧.-

ការិយាល័យការងារ ឃ្លាំងផ្ទុកសម្ភារៈ ជម្រកកម្មករ គ្រឿងចក្រ និង សកម្មភាពសាងសង់ត្រូវរៀបចំ និងប្រព្រឹត្តទៅនៅក្នុងរបងហ៊ុមព័ទ្ធនៃការដ្ឋាន ឬ ការដ្ឋានរោប ឬទីកន្លែងដែលធានាបានសណ្តាប់ធ្នាប់ និង សន្តិសុខសាធារណៈ ។

ប្រការ ៨.-

ចំពោះសំណង់ដែលត្រូវប្រើគ្រឿងចក្របរិក្ខារលើកស្ទូច ហើយអាចធ្វើឱ្យប៉ះពាល់ដល់ការធ្វើដំណើរលើផ្លូវសាធារណៈ ម្ចាស់សំណង់ត្រូវ :

-សុំការអនុញ្ញាតពីអាជ្ញាធរដែនដី ដើម្បីបិទផ្លូវសម្រាប់ការដំឡើងគ្រឿងផ្គុំសំណង់ ហើយធ្វើផ្លូវវាងជាបណ្តោះអាសន្ន

-បំពាក់ភ្លើងសញ្ញាសម្គាល់ លើផ្លូវដែលបិទ ដើម្បីសុវត្ថិភាព និង សណ្តាប់ធ្នាប់សាធារណៈនៅពេលយប់ ។

ប្រការ ៩.-

ក្នុងករណីការសាងសង់មានបុគ្គលសរគ្រោះ ម្ចាស់សំណង់ និង អ្នកម៉ៅការសាងសង់ត្រូវ :

-មានកាតព្វកិច្ចអនុញ្ញាតឱ្យមន្ត្រីបច្ចេកទេស ដែលមានសមត្ថកិច្ចចូលពិនិត្យក្នុងការដ្ឋាន

-ជៀសវាងការប៉ះពាល់ដល់គ្រឿងផ្គុំផ្នែកក្រោមដី

-ធានាសុវត្ថិភាពអគារដែលស្ថិតនៅជុំវិញបរិវេណការដ្ឋាន

-រៀបចំសណ្តាប់ធ្នាប់ការងារឱ្យបានសមស្រប តាមលក្ខណៈបច្ចេកទេស ។

ប្រការ ១០.-

ម្ចាស់សំណង់ និង អ្នកម៉ៅការសាងសង់ត្រូវបំពាក់ប្រដាប់ការពារសុវត្ថិភាព មានមួកសុវត្ថិភាព, ស្រោមដៃ, ស្បែកជើង, ខ្សែក្រវ៉ាត់សុវត្ថិភាពសម្រាប់ឈរនៅទីខ្ពស់ និង ឧបករណ៍ការពារដទៃទៀតដល់បុគ្គលិក កម្មករជាប្រចាំក្នុងការដ្ឋាន ។

ប្រការ ១១.-

ពេលសាងសង់រួចជាស្ថាពរ ម្ចាស់សំណង់ត្រូវផ្ញើរបាយការណ៍ស្តីពីដំណើរការសាងសង់របស់ខ្លួន និង សុំលិខិតបិទការដ្ឋានសំណង់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ឬ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី ខេត្ត ក្រុង ។

សំណុំឯកសារដើម្បីសុំលិខិតបិទការដ្ឋាន :

១-ពាក្យសុំរបស់ម្ចាស់សំណង់

២-លិខិតអនុញ្ញាតបើកការដ្ឋាន

៣-របាយការណ៍អំពីដំណើរការសាងសង់ ។

ប្រការ ១២.-

ពេលទទួលបានលិខិតបិទការដ្ឋានរួចហើយ ម្ចាស់សំណង់ត្រូវដាក់ពាក្យសុំវិញ្ញាបនប័ត្របញ្ជាក់ភាពត្រឹមត្រូវ នៃ សំណង់នោះទៅ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ឬ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី ខេត្តក្រុង មុនបើកការប្រើប្រាស់ ។

ប្រការ ១៣.-

ពេលបញ្ចប់ការដ្ឋានសាងសង់ជាស្ថាពរ ម្ចាស់សំណង់ត្រូវរុះរើ របងហ៊ុមព័ទ្ធការដ្ឋាន និង ដឹកជញ្ជូនកាកសំណល់ឱ្យបានស្អាត។

ប្រការ ១៤.-

ការដ្ឋានដែលប្រព្រឹត្តល្មើសនឹងបញ្ញត្តិដូចមានចែងក្នុងប្រការ៣ អាជ្ញាធរមានសមត្ថកិច្ចត្រូវផ្អាកការងារការដ្ឋានជាបណ្ដោះអាសន្ន ។ក្នុងករណីម្ចាស់ការដ្ឋានរឹងរូសនៅតែបន្តការសាងសង់អាជ្ញាធរមានសមត្ថកិច្ចត្រូវមានវិធានការដកហូត សម្ភារៈសាងសង់ទាំងនោះ ហើយប្ដឹងទៅតុលាការ ។

ការដ្ឋានដែលប្រព្រឹត្តល្មើសនឹងករណីដូចមានចែងក្នុងប្រការ៤.៧.៩.១០.១១ និង ប្រការ១២ មន្ត្រីជំនាញមានសមត្ថកិច្ចត្រូវធ្វើការណែនាំឱ្យម្ចាស់សំណង់បំពេញលក្ខខណ្ឌខ្វះខាតទាំងនោះ ឬ ធ្វើលិខិតជូនដំណឹងឱ្យកែតម្រូវចំណុចខុសឆ្គងនឹងប្លង់ដែលបានអនុញ្ញាត ឬខុសនឹង នគរូបនីយបញ្ញត្តិ ។ ក្រោយបានទទួលលិខិតជូនដំណឹងរយៈពេល១៥ថ្ងៃ បើគ្មានការកែតម្រូវទេ អាជ្ញាធរមានសមត្ថកិច្ចត្រូវផ្អាកការដ្ឋានជាបណ្ដោះអាសន្ន ។ក្នុងករណីម្ចាស់សំណង់

មិនព្រមអនុវត្តតាមការណែនាំ អាជ្ញាធរមានសមត្ថកិច្ចត្រូវរុះរើ រឹបអូសសម្ភារៈសាងសង់ទាំងអស់ ហើយប្តឹងទៅតុលាការ ។

ការដ្ឋានដែលល្មើសនឹងករណីដូចមានចែងក្នុងប្រការ ៥ . ៦ និងប្រការ ៨ អាជ្ញាធរមានសមត្ថកិច្ចត្រូវជាកពិន័យ ហើយបង្ខំឱ្យម្ចាស់ការដ្ឋានអនុវត្តតាមការណែនាំអំពីរបៀបរៀបចំសណ្តាប់ធ្នាប់សន្តិសុខសាធារណៈ ។ ក្នុងករណីម្ចាស់សំណង់នៅតែមិនគោរពតាមការណែនាំ អាជ្ញាធរមានសមត្ថកិច្ចត្រូវរឹបអូសសម្ភារៈសំណង់ទាំងនោះ ។

ប្រការ ១៥.-

ការដ្ឋានដែលត្រូវបានផ្អាកជាបណ្តោះអាសន្ន ដូចមានចែងក្នុងវាក្យខណ្ឌទី១ និងវាក្យខណ្ឌទី២ក្នុងប្រការទី ១៤ នៃប្រកាសនេះត្រូវបានអនុញ្ញាតឱ្យបើកតាមផ្លូវច្បាប់ជាថ្មីឡើងវិញ លុះត្រាតែបានបំពេញលក្ខខណ្ឌគ្រប់គ្រាន់តាមការណែនាំរបស់អាជ្ញាធរមានសមត្ថកិច្ច ។

សំណុំបែបបទនៃការបើកការដ្ឋានឡើងវិញ មានដូចខាងក្រោម :

១-ពាក្យសុំរបស់ម្ចាស់សំណង់

២-លិខិតអនុញ្ញាតបើកការដ្ឋានចាស់

៣-លិខិតផ្អាកការដ្ឋាន

៤-លិខិតបញ្ជាក់អំពីការបំពេញបានសព្វគ្រប់ នៃ លក្ខខណ្ឌខ្វះខាត ។

ប្រការ ១៦.-

ម្ចាស់សំណង់ និងអ្នកម៉ៅការសាងសង់ ត្រូវគោរពច្បាប់ការងារ នៃ ព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ១៧.-

នាយកខុទ្ទកាល័យ អគ្គនាយក នៃ គ្រប់អគ្គនាយកដ្ឋាន ប្រធាន មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី ខេត្ត ក្រុង និង ប្រធានការិយាល័យ រៀបចំដែនដី នគរូបនីយកម្ម សំណង់ និង ភូមិបាល ស្រុក ខណ្ឌ ត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី២០ ខែ[illegible] ឆ្នាំ២០០១

រដ្ឋមន្ត្រី

ចម្លងជូន

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងស្ថាប័ន
- គ្រប់សាលាខេត្ត ក្រុង
- ដូចប្រការ ១៧
- ឯកសារ-កាលប្បវត្តិ